ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិគន្ធបុប្ផាកម្ពុជា
លេខ :.................ម.គ.ក........

ថ្ងៃ ចន្ទ ១២កើត ខែ មាឃ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីពិធីប្រគល់-ទទួលថវិកាបរិច្ចាគជូន "មូលនិធិគន្ធបុប្ផាកម្ពុជា" រវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនិងសមាគមសម្ព័ន្ធខ្មែរ-ចិននៅកម្ពុជា

នៅព្រឹកថ្ងៃចន្ទ ទី ២៥ ខែ មករា ឆ្នាំ ២០២១, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាលនៃ **"មូលនិធិគន្ធបុប្ផាកម្ពុជា"** បានទទួលជួបសំណេះសំណាលជាមួយប្រតិភូនៃសមាគមសម្ព័ន្ធខ្មែរ-ចិននៅកម្ពុជា ក្នុងឱកាសដែលសមាគម នាំមកនូវថវិកាវិភាគទានសប្បុរសធម៌ប្រចាំឆ្នាំលើកទី ៣ មកជូន **"មូលនិធិគន្ធបុប្ផាកម្ពុជា"** ។

វិភាគទានសប្បុរសធម៌ប្រចាំឆ្នាំ លើកទី ៣ នេះ, សមាគមសម្ព័ន្ធខ្មែរ-ចិននៅកម្ពុជា ដឹកនាំដោយលោកឧកញ៉ា **ពុង ឃាវសែ** ជាប្រធានសមាគម និងជាប្រធានក្រុមហ៊ុនអណិកជន (Oversea Cambodia Investment Corporation - OCIC) បាននាំមកនូវថវិកា ចំនួន ១២៥ ៦០០ (មួយរយម្ភៃប្រាំពាន់ ប្រាំមួយរយ) ដុល្លារអាមេរិក និង ១ ៨១៥ ១៨៨ ៤៤១ (មួយប៊ីលាន ប្រាំបីរយដប់ប្រាំលាន មួយរយប៉ែតសិបប្រាំបីពាន់ បួនរយសែសិបមួយ) រៀល ជូន **"មូលនិធិគន្ធបុប្ផាកម្ពុជា"** ដែលវិភាគទានសប្បុរសធម៌ទទួលបានពីទឹកចិត្តសប្បុរសធម៌ដ៏ថ្លៃថ្លារបស់គណៈគ្រប់គ្រង និងបុគ្គលិកនៅតាមបណ្តាក្រុមហ៊ុននានា លោកគ្រូ អ្នកគ្រូ និងសមាជិកនានាក្នុងក្របខណ្ឌនៃសមាគមសម្ព័ន្ធខ្មែរ-ចិននៅកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី,** ក្នុងនាមប្រធានក្រុមប្រឹក្សាបរធនបាលនៃ **"មូលនិធិគន្ធបុប្ផាកម្ពុជា"**, បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ជាថ្មីម្តងទៀតចំពោះទឹកសប្បុរសធម៌ និងការចូលរួមជាប្រចាំពីសំណាក់សមាគមសម្ព័ន្ធខ្មែរ-ចិននៅកម្ពុជា វិស័យឯកជន ជាពិសេស បណ្តាធុរជន និងវិនិយោគិនចិននៅកម្ពុជា ដែលតែងតែបង្ហាញពីស្មារតី និងទឹកចិត្តដ៏ថ្លៃថ្លាក្នុងការចូលរួមចំណែកជាប្រចាំជាមួយរាជរដ្ឋាភិបាលក្នុងការផ្តល់ការគាំពារ និងលើកកម្ពស់សុខុមាលភាពកុមាររាប់លាននាក់នៅកម្ពុជា ។

ឆ្លៀតក្នុងឱកាសនេះ, លោកឧកញ៉ា **ពុង ឃាវសែ** បានសម្តែងនូវការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង ការគិតគូរ និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ចំពោះសុខមាល និងសុខភាពកុមារកម្ពុជា តាមរយៈ "**មូលនិធិគន្ធបុប្ផាកម្ពុជា**" ។ ជាមួយគ្នានេះ, **លោកឧកញ៉ា** ក៏បានបានថ្លែងអំណរគុណយ៉ាង ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលដែលតែងតែគាំទ្រដល់វិស័យធុរកិច្ចរបស់វិនិយោគិនចិន ក៏ដូចជាសមាគមន៍ខ្មែរ-ចិន ផងដែរ ។ **លោកឧកញ៉ា** ក៏បានសន្យាថានឹងបន្តបំផុសចលនាគាំទ្រ និងចូលរួមជាមួយ "**មូលនិធិគន្ធបុប្ផាកម្ពុជា**" ជាប្រចាំ ។

ជាថ្មីម្តងទៀត, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណ និងបានលើកទឹកចិត្តឱ្យក្រុមហ៊ុននានាដែលជាសមាជិករបស់សមាគមសម្ព័ន្ធខ្មែរ-ចិននៅកម្ពុជា បន្តខិតខំ និងពង្រីកការវិនិយោគឱ្យបានកាន់តែទូលំទូលាយ ដើម្បីការអភិវឌ្ឍទាំងក្រុមហ៊ុន និងទាំងការរួមចំណែកអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានអំពាវនាវ និងលើកទឹកចិត្តដល់សមាជិករបស់សមាគមសម្ព័ន្ធខ្មែរ-ចិន ក៏ដូចជា ក្រសួង-ស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជន និងសាធារណជន ឱ្យបន្តចូលរួមបរិច្ចាគ និងចូលជាសមាជិករបស់មូលនិធិគន្ធបុប្ផាកម្ពុជាថែមទៀត ដើម្បីរួមគ្នាធានាឱ្យបាននូវនិរន្តរភាពរបស់មន្ទីរពេទ្យគន្ធបុប្ផា និងដើម្បីភាពញញឹមរបស់កុមារ ក្រោមដំបូលសុខសន្តិភាព ។